
www.kidsofdestiny.org
Kids of Destiny®

## 1.04 កាអ៊ីន និងអេបិលដែលជាបងប្អូនដំបូងបង្អស់

នៅពេលដែលព្រះទ្រង់បានបង្កើតផ្ទៃមេឃនិងផែនដី ព្រះអង្គក៏បានបង្កើតមនុស្សដែរ។ បុរសនិងស្ត្រីដំបូងគឺ អ័ដាមជាបុរស និងអេវ៉ាជាស្ត្រី។ ព្រះបានបង្កើតពួកគេជាប្តីប្រពន្ធដំបូង។ ព្រះក៏បានបង្កើតពួកគេជាម្តាយនិងឪពុកដំបូងគេដែរ។ ថ្ងៃមួយនៅពេលនាងអេវ៉ាស្តាប់ខ្មាំងសត្រូវរបស់ព្រះ ឈ្មោះសាតាំងនាងក៏មិនស្តាប់បង្គាប់ព្រះដ៏ជាព្រះ។ នាងបានបរិភោគផ្លែដឹងខុសត្រូវ ដែលព្រះបានហាមនាង និងអ័ដាមកុំឲ្យបរិភោគ។

អ័ដាមក៏បានបរិភោគពីដើមឈើនោះដែរ។ ដោយសារតែការមិនស្តាប់បង្គាប់របស់ពួកគេ នោះហៅថា អំពើរបាបពួកគេត្រូវតែចាកចេញពីសួនច្បារដ៏ស្រស់ស្អាត ដែលព្រះទ្រង់បានបង្កើតសម្រាប់ពួកគេ។ ឥឡូវពួកគេត្រូវខិតខំធ្វើការដើម្បីរស់នៅ។ មួយរយៈក្រោយមក អ័ដាមនិងអេវ៉ាក៏មានកូន។ ពួកគេមានកូនប្រុសពីរនាក់។ ឈ្មោះរបស់ពួកគេគឺ កាអ៊ីន និងអេបិល។ អេបិលបានមើលថែរក្សាហ្វូងសត្វ ។ កាអ៊ីនធ្វើការជាកសិករ។ កាអ៊ីនបានដាំរុក្ខជាតិនិងបន្លែ។ កាអ៊ីននិងអេបិលត្រូវបានបង្រៀនឲ្យចេះថ្វាយតង្វាយទៅព្រះ។

នៅថ្ងៃមួយ កាអ៊ីនបានយកតង្វាយពីដំណាំរបស់គាត់ទៅថ្វាយព្រះ។ អេបិលបានយកសត្វល្អបំផុត មកធ្វើជាតង្វាយពីហ្វូងសត្វរបស់គាត់។ ព្រះទ្រង់ចូលចិត្តអេបិលនិងតង្វាយរបស់គាត់ ប៉ុន្តែទ្រង់មិនពេញចិត្តនឹងកាអ៊ីននិងតង្វាយរបស់គាត់ទេ។ ព្រះអាចមើលឃើញនៅក្នុងចិត្តរបស់បងប្អូនម្នាក់ៗ។ កាអ៊ីនបានខឹងនឹងព្រះ គាត់គិតថា តង្វាយរបស់គាត់គួរតែល្អដូចប្អូនប្រុសរបស់គាត់ដែរ។ កាអ៊ីនខឹងយ៉ាងខ្លាំងហើយបានសម្លាប់ប្អូនប្រុសរបស់គាត់ឈ្មោះអេបិល។ ព្រះអម្ចាស់ទតឃើញអ្វីៗដែលបានកើតឡើង ព្រោះព្រះដ៏ជាព្រះទ្រង់ទតឃើញអ្វីៗទាំងអស់។ ព្រះទ្រង់មានបន្ទូលទៅកាន់កាអ៊ីនថា "អេបិលប្អូនរបស់អ្នកនៅឯណា?" កាអ៊ីនបានកុហកព្រះហើយនិយាយថា គាត់មិនដឹងទេ។ ព្រះទ្រង់ដឹងថាកាអ៊ីនកុហក។ ព្រះទ្រង់មានព្រះបន្ទូលទៅគាត់ថា៖ «តើឯងបានធ្វើអ្វីចំពោះប្អូនប្រុសឯង ឥឡូវនេះឯងនឹងត្រូវបណ្តាសា ក្នុងជីវិតរបស់ឯងពេញមួយជីវិត។

ឥឡូវឯងនឹងអណ្តែតទៅមកលើផែនដី។ មិនថាឯងព្យាយាមយូរប៉ុនណាទេ ឯងនឹងមិនអាចដាំដំណាំបានល្អនៅលើដីបានទេ។ ឯងនឹងក្លាយជាមនុស្សសាត់ព្រាត់គ្មានផ្ទះសម្បែង។ កាអ៊ីនបានទូលទៅព្រះថា៖ «ទណ្ឌកម្មនេះធ្ងន់ណាស់សំរាប់ខ្ញុំ! ខ្ញុំមិនអាចទទួលបាននូវជីវិតដ៏លំបាកនេះបានទេ។ ព្រះអង្គបានចាត់ទូលបង្គំឲ្យចាកចេញពីទឹកដីនេះនិងពីព្រះ អង្គ។ ឥឡូវនេះអ្នកណាដែលរកឃើញខ្ញុំនឹងសម្លាប់ខ្ញុំ។ ព្រះទ្រង់មានបន្ទូលទៅកាអ៊ីនថា"ទេ។ ប្រសិនបើអ្នកណាសម្លាប់ឯងពួកគេនឹងត្រូវទទួលទណ្ឌកម្ម៧ដងធ្ងន់ជាងទណ្ឌកម្មដែលយើងបានដាក់ទៅលើឯងឥឡូវនេះទៅទៀត។ ព្រះបានដៅចំណាំកាអ៊ីន ដូច្នេះអ្នកផ្សេងទៀតនឹងដឹងហើយនឹងមិនសម្លាប់គាត់ទេ។ បន្ទាប់មកកាអ៊ីនបានចាកចេញពីគ្រួសាររបស់គាត់ហើយត្រូវរស់នៅក្នុងទឹកដីមួយទៀត។ បងប្អូនគួរតែស្រឡាញ់គ្នា។ កាអ៊ីនត្រូវបានដាក់ទណ្ឌកម្មដ៏ក្រៀមក្រំចំពោះកំហឹងរបស់គាត់ចំពោះព្រះ និងអេបិលជាប្អូនរបស់គាត់។ ព្រះត្រូវបង្ហាញកាអ៊ីនថា គាត់បានធ្វើខុសនិងអ្វីដែលគាត់បានធ្វើខុស។

រឿងរ៉ាវរបស់បងប្អូនទាំងនេះគឺជារឿងសោកសៅ។ ការជ្រើសរើសមិនគោរពព្រះ គឺបំបែកយើងពីទ្រង់និងព្រះពររបស់ទ្រង់ បើយើងខឹងនឹងបងប្អូនប្រុសស្រីរបស់យើង យើងគួរតែសុំឱ្យព្រះជួយយើងឲ្យអភ័យទោសឱ្យពួកគេ ហើយស្រឡាញ់ពួកគេម្តងទៀត ។

(លោកុប្បត្តិ ៤)

1.04 **កាអ៊ីន និងអេបិល**

**សេចក្តីណែនាំសម្រាប់គ្រូបង្រៀន កំណត់សំគាល់**

១) អ័ដាម និងអេវ៉ាគឺជាបុរសនិងស្ត្រីដំបូងដែលព្រះទ្រង់បានបង្កើតមក។ នៅពេលអ័ដាម និងអេវ៉ាមិនស្តាប់បង្គាប់ព្រះ ពួកគេត្រូវតែចាកចេញពីសួនច្បារដ៏ស្រស់ស្អាត ដែលព្រះទ្រង់បានបង្កើតមក ។ ពួកគេត្រូវខិតខំធ្វើការដើម្បីរស់នៅ ។

២) អ័ដាមនិងអេវ៉ាក៏ជាម្តាយនិងឪពុកដំបូងដែរ ។ ពួកគេមានកូនប្រុសពីរនាក់ឈ្មោះកាអ៊ីន និងអេបិល ។

៣) កាអ៊ីនគឺជាកសិករដាំដំណាំ និងបន្លែ។ អេបិលគឺជាអ្នកគង្វាលហ្វូងសត្វ ។ ដល់ពេលដែលត្រូវថ្វាយតង្វាយដល់ព្រះ អេបិលបានថ្វាយសត្វល្អបំផុតពីហ្វូងសត្វរបស់គាត់ ។ កាអ៊ីនបាននាំភោគផលខ្លះរបស់គាត់មកថ្វាយព្រះ ។

៤)ព្រះទ្រង់សព្វព្រះហឫទ័យនឹងតង្វាយរបស់អេបិលណាស់ ព្រោះអេបិលបានថ្វាយចេញពីដួងចិត្តរបស់គាត់ ប៉ុន្តែព្រះអម្ចាស់មិនព្រមទទួលតង្វាយរបស់កាអ៊ីនទេ។ កាអ៊ីនខឹងយ៉ាងខ្លាំងហើយបានសម្លាប់ប្អូនរបស់គាត់ឈ្មោះអេបិលទៅ។ ព្រះទ្រង់បានទតឃើញអ្វីដែលគាត់បានធ្វើ ។

៥) ព្រះទ្រង់បានប្រាប់កាអ៊ីនថា គាត់ត្រូវចាកចេញពីទឹកដីនោះ ឥឡូវឯងនឹងអណ្តែតទៅមកលើផែនដី ។ គាត់នឹងរស់នៅសាត់ព្រាត់ ដែលគ្មានផ្ទះសម្បែង ។ ព្រះទ្រង់បានដៅចំណាំកាអ៊ីន ដើម្បីកុំឲ្យអ្នកណាសម្លាប់គាត់ កាអ៊ីនក៏ត្រូវចាកចេញពីព្រះវត្តមានរបស់ព្រះដែរ ។ ដោយការជ្រើសរើសមិនគោរពព្រះ នោះទ្រង់បំបែកយើងពីទ្រង់ និងដកព្រះពរ របស់ទ្រង់ផង ។

**សំណួរ:**

១) តើអ្នកណាជាឪពុកនិងម្តាយដំបូងគេបង្អស់?

២) តើបងប្អូនប្រុសដំបូងគេបង្អស់មានឈ្មោះអ្វីខ្លះ?

៣) តើអ្នកណាដែលធ្វើការជាមួយសត្វ?

៤) តើអ្នកណាដែលធ្វើការជាអ្នកដាំដំណាំ?

៥) តើដង្វាយរបស់អ្នកណា ដែលព្រះសព្វព្រះហឫទ័យជាងគេ? ហេតុអ្វី?

៦) តើមានអ្វីកើតឡើងដល់កាអ៊ីនបន្ទាប់ពីគាត់បានសម្លាប់ប្អូនប្រុសរបស់គាត់?

**ចម្លើយ:**

១) អ័ដាមនិងអេវ៉ាគឺជាឪពុកនិងម្តាយដំបូងគេបង្អស់ ។

២) បងប្អូនដំបូងបង្អស់មានឈ្មោះកាអ៊ីន និងអេបិល ។

៣) អេបិលជាអ្នកចិញ្ចឹមសត្វ ។

៤) កាអ៊ីនបានធ្វើការជាអ្នកដាំដំណាំ ។

៥) ព្រះសព្វព្រះហឫទ័យនឹងតង្វាយរបស់អេបិល ។ ព្រោះអេបិលបានថ្វាយដង្វាយចេញពីចិត្តរបស់គាត់ ។

៦) ព្រះបានប្រាប់កាអ៊ីនឲ្យចាកចេញពីទឹកដីនោះ ហើយចាកចេញពីវត្តមានរបស់ព្រះ ។ គាត់នឹងត្រូវសាត់ព្រាត់នៅលើផែនដី ។

